## មេរៀនទី១៦ - បញ្ហា រ៉េស៊ីស្ទ័រ (Resistor Troubles)

រ៉េស៊ីស្ទ័រគឺជាគ្រឿងមួយដែលងាយពិនិត្យរកបញ្ហា ព្រោះពេលរ៉េស៊ីស្ទ័រខូច វាតែងតែមានចំនួនអូមធំច្រើនក្រៃលែង ។

*ឧទាហរណ៍ខ្លះៗ ៖*

១. ពេលមួលបិទបើកសម្លេង មានសម្លេងក្រេវក្រត - បញ្ហានេះច្រើនតែបណ្តាលមកពីប្រដាប់បិទបើកសម្លេងដែលជារ៉េស៊ីស្ទ័រ មានភាពរេចសឹករអស់ជាតិរ៉េស៊ីស្ទិន្ស ឬមកពីខូចមុខផ្សារ ។

២. អត់មានចរន្ត ឬខ្សោយភ្លើងដែលត្រូវនាំចេញមកពីរ៉េស៊ីស្ទ័រនោះ - បញ្ហានេះអាចបណ្តាលមកពីរ៉េស៊ីស្ទ័រហ្នឹងរបើកជើង ឬមកពីរ៉េស៊ីស្ទ័រហ្នឹងខូចដែលបណ្តាលអោយមានចំនួនអូមច្រើនពេក ។

*របៀបត្រួតពិនិត្យ ៖*

ត្រូវបិទភ្លើង រួចដោះយករ៉េស៊ីស្ទ័រដែលគួរអោយសង្ស័យជាងគេយកមកពិនិត្យ ។

